**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើមោឃភាពប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបង្កាន់ដៃ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងឯកសារផ្សេងៗទៀត ដែលបញ្ជាក់ពីសិទ្ធិកាន់កាប់ដីមិនស្របច្បាប់ ក្នុងតំបន់វិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន YEEJIA Tourism Development Co., Ltd នៃឧទ្យានជាតិព្រះសីហនុ "រាម" ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ភូមិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**មាត្រា ១:** ចាត់ទុកជាមោឃៈ នូវប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ

$C_{II}$: 0616 ; $C_{II}$: 0617 ; $C_{II}$: 0190 ; $C_{II}$: 0191 ; $C_{II}$:0192 ; $C_{II}$: 0193 ; $C_{II}$: 0194 ; $C_{II}$:0195

$C_{II}$: 0196 ; $C_{II}$: 0197 ; $C_{II}$: 0198 ; $C_{II}$: 0199 ; $C_{II}$: 0200 ; $C_{II}$: 0201 និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងសិទ្ធិកាន់កាប់ដីមិនស្របច្បាប់ ស្ថិតនៅក្នុងតំបន់វិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន YEEJIA Tourism Development Co., Ltd ក្នុងឧទ្យានជាតិព្រះសីហនុ "រាម" ខេត្តព្រះសីហនុ ។

**មាត្រា ២:** ប្រគល់សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ នូវដីដែលបានចែងក្នុងមាត្រា ១ ខាងលើឱ្យទៅក្រសួងបរិស្ថានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្តព្រះសីហនុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ